Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

**ស្ថានទូតស្វីសប្រចាំប្រទេសថៃឡង់ដ៍**

**មជ្ឈមណ្ឌលកុងស៊ុលប្រចាំតំបន់**

ផ្នែកទិដ្ឋាការ

# ទិដ្ឋាការស្ហេនហ្កេន (Schengen) សំរាប់ទៅសួរសុខទុក្ខបងប្អូន ក្រុមគ្រួសារ ឬមិត្តភ័ក្រ

លោក-លោកស្រីដែលមានបំណងស្នើសុំទិដ្ឋាការស្ហេនហ្កេន(ទិដ្ឋាការប្រភេទC - រយៈពេលស្នាក់នៅមិនលើសពី៩០ថ្ងៃ) ត្រូវដាក់ពាក្យស្នើសុំទិដ្ឋាការ និងធ្វើការណាត់ជួបរបស់ខ្លួនតាមប្រព័ន្ធអនឡាញដោយគ្រាន់តែចុចលើតំណភ្ជាប់មួយនេះ : www.swiss-visa.ch ។ លោក-លោកស្រី ត្រូវតែបង្ហាញវត្តមានរបស់ខ្លួននៅទីភ្នាក់ងារកុងស៊ុលស្វីសប្រចាំនៅទីក្រុងភ្នំពេញ ទៅតាមពេលវេលាដែលបានស្នើសុំដើម្បីដាក់សំណុំឯកសារ ដែលបានបំពេញតាមប្រព័ន្ធអនឡាញរបស់ខ្លួនដោយភ្ជាប់មកជាមួយនូវឯកសារតំរូវការចាំបាច់នានា-ដើម្បីផ្តិតស្នាមក្រយៅដៃនិងបង់ថ្លៃទិដ្ឋាការជាសាច់ប្រាក់។ ទីភ្នាក់ងារកុងស៊ុលស្វីសនឹងមិនទទួលពាក្យស្នើសុំទិដ្ឋាការរបស់ លោក-លោកស្រីដោយពុំមានធ្វើការណាត់ជួបជាមុននោះឡើយ។

## ១. ឯកសារចាំបាច់សំរាប់អ្នកសុំទិដ្ឋាការ

- បែបបទសុំទិដ្ឋាការសំរាប់រយៈពេលខ្លីត្រូវបំពេញ ចុះកាលបរិច្ឆេទ និងហត្ថលេខាអោយបានត្រឹមត្រូវ។ សំរាប់អនីតិជនដែលមានអាយុក្រោម១៨ឆ្នាំ បែបបទសុំទិដ្ឋាការត្រូវចុះហត្ថលេខាដោយឪពុកម្តាយ ឬ អាណាព្យាបាលអនីតិជននោះ។
- រូបថត២សន្លឹក: ពណ៌ធម្មជាតិ ថតថ្មីៗ ទំហំ ៣,៥-៤សង់ទីម៉ែត្រ ផ្ទៃខាងក្រោយស ទំហំនៃផ្ទៃមុខពី ៧០-៨០%នៃផ្ទៃរូបថតទាំងមូល។
- លិខិតឆ្លងដែន: ត្រូវនៅមានសុពលភាពយ៉ាងតិចចំនួន៣ខែបន្ទាប់ពីថ្ងៃចាកចេញពីទឹកដីនៃរដ្ឋសមាជិកស្ហេនហ្កេនហើយត្រូវនៅមាន២ទំព័រទំនេរ។ប្រសិនបើអាចធ្វើបាន សូមភ្ជាប់មកជាមួយនូវលិខិតឆ្លងដែនចាស់របស់លោក អ្នកមកជាមួយផង។ សំរាប់ជនបរទេសដែលស្នាក់នៅក្នុងប្រទេសទី៣ ត្រូវភ្ជាប់មកជាមួយនូវលិខិតការងារ និង/ឬលិខិតអនុញ្ញាតអោយស្នាក់ព្រមជាមួយទិដ្ឋាការចេញ-ចូលដែលមានសុពលភាព។
- ច្បាប់ថតចំលងលិខិតឆ្លងដែនមួយច្បាប់: ទំព័រដែលមានព័ត៌មានផ្ទាល់ខ្លួន និងទំព័រដែលមានទិដ្ឋាការសែនហ្កេននាពេលកន្លងមក។
- លិខិតកក់សំបុត្រយន្តហោះ(ទៅ-មក) : លោក អ្នកពុំត្រូវទិញសំបុត្រយន្តហោះពេលដែលមិនទាន់ទទួលបានទិដ្ឋាការនោះទេ។ ទីភ្នាក់ងារកុងស៊ុលស្វីសប្រចាំនៅទីក្រុងភ្នំពេញ ក៏ដូចជាមជ្ឈមណ្ឌលកុងស៊ុលប្រចាំតំបន់មិនទទួលខុសត្រូវក្នុងករណីពន្យារពេលនៃការធ្វើដំណើរ ឬផុតកំណត់នៃការប្រើប្រាស់របស់សំបុត្រយន្តហោះក្នុងករណីទិដ្ឋាការត្រូវបានបដិសេធនោះឡើយ។
- លិខិតធានារ៉ាប់រងសុខភាពនិងការធ្វើដំណើរ: ព័ត៌មានសំខាន់ស្តីពីលក្ខខ័ណ្ឌនានាមាននៅទីនេះ។
- លិខិតបញ្ជាក់ការងារ ឬលិខិតបញ្ជាក់ការសិក្សានៅសាលា ឬមហាវិទ្យាល័យ លិខិតបញ្ជាក់បញ្ជិកាពាណិជ្ជកម្ម(ប៉ាតង់) : ត្រូវផ្តល់ជាច្បាប់ដើម និងច្បាប់ថតចម្លង។

- របាយការណ៍ធនាគាររយៈពេលបីខែចុងក្រោយ: ប្រសិនបើអ្នកស្នើសុំនោះមិនមានមធ្យោបាយហិរញ្ញវត្ថុគ្រប់គ្រាន់ សេចក្តីបញ្ជាក់នៃការគាំទ្រនឹងតម្រូវអោយមានជាចាំបាច់។
- ទំនាក់ទំនងសាច់ញាតិ: ប្រសិនបើអ្នកសុំទិដ្ឋាការ និងអ្នកធានាជាសាច់ញាតិនឹងគ្នា ទំនាក់ទំនងនោះត្រូវតែបង្ហាញតាមរយៈឯកសារផ្លូវការនានាដូចជា៖ សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រកំណើត សៀវភៅគ្រួសារ។ល។ ឯកសារនោះត្រូវផ្តល់ជាច្បាប់ដើម និងច្បាប់ថតចំលង។
- សំបុត្របញ្ជាក់កំណើត: ចំពោះអនីតិជនអាយុក្រោម១៨ឆ្នាំតែប៉ុណ្ណោះ។
  ត្រូវផ្តល់ជាច្បាប់ដើម និងច្បាប់ថតចម្លង។ នៅពេលដែលអនីតិជនធ្វើដំណើរតែម្នាក់ឯងដោយគ្មានឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជននោះទៅជាមួយ លិខិតអនុញ្ញាតិអោយធ្វើដំណើរ(Parental Consent) ដែលចេញដោយអជ្ញាធរមានសមត្ថកិច្ចកម្ពុជា (សាលាឃុំ-សង្កាត់) ត្រូវបានស្នើរសុំជាច្បាប់ដើមដោយភ្ជាប់ជាមួយនឹងសេចក្តីថតចម្លងនៃលិខិតឆ្លងដែនរបស់ឪពុកម្តាយអនីតិជននោះ។ ឪពុកម្តាយនៃអនីតិជននោះ ត្រូវអញ្ជើញមកបញ្ជនៃទីភ្នាក់ងារកុងស៊ុលស្វីសដោយផ្ទាល់ដើម្បីចុះហត្ថលេខាលើបែបបទសុំទិដ្ឋាការរបស់កូនខ្លួន។ប្រសិនបើអនីតិជននោះមានតែឪពុក ឬម្តាយតែម្ខាងឯកសារឬលិខិតដែលបញ្ជាក់ថាឪពុក ឬម្តាយនោះមានសិទ្ធិគ្រប់គ្រងកូនត្រូវបានស្នើរសុំបន្ថែម។

## ២. ឯកសារចាំបាច់សំរាប់អ្នកធានា

- លិខិតអញ្ជើញដោយមានចុះហត្ថលេខាត្រឹមត្រូវ: លិខិតអញ្ជើញពុំមានទំរង់ជាក់លាក់ណាមួយនោះទេ។ លិខិតនោះត្រូវមានចំនុចមួយចំនួនដូចជា៖ អ្នកធានារងចាំការមកដល់របស់អ្នកសុំទិដ្ឋាការ អស័យដ្ឋានលំអិតរបស់អ្នកធានា និងអ្នកសុំទិដ្ឋាការ កាលបរិច្ឆេទនៃការរៀបចំលិខិតអញ្ជើញ ព្រមទាំងហត្ថលេខារបស់អ្នកធានា។ ចំនុចមួយចំនួនទៀតដែលអ្នកធានាត្រូវសរសេរផងដែររួមមាន៖ ការផ្តល់ការស្នាក់នៅ និងហូបចុកដល់អ្នកសុំទិដ្ឋាការ ស្ថានភាពពាក់ព័ន្ធផ្សេងទៀត និងមូលហេតុនៃការស្នាក់នៅក្នុងប្រទេសស្វីសរបស់អ្នកសុំទិដ្ឋាការ។
  គំរូលិខិតអញ្ជើញមានស្រាប់នៅលើគេហទំព័ររបស់ពួកយើងជាភាសាអាឡឺម៉ង់ និងបារាំង។
- ច្បាប់ថតចំលងលិខិតឆ្លងដែនស្វីស ឬលិខិតអនុញ្ញាតអោយស្នាក់នៅ: មួយច្បាប់។
- របាយការណ៍ធនាគាររបស់អ្នកធានារស់នៅប្រទេសកម្ពុជា
  ប្រសិនបើអ្នកធានាស្នាក់នៅក្នុងប្រទេសកម្ពុជា និងបានចុះបញ្ជីជាមួយមជ្ឈមណ្ឌលកុងស៊ុលប្រចាំតំបន់នៅទីក្រុងបាងកក របាយការណ៍ធនាគាររយៈពេលបីខែចុងក្រោយរបស់គាត់ត្រូវបានស្នើរសុំដោយភ្ជាប់ជាមួយនឹងពាក្យសុំទិដ្ឋាការ (ច្បាប់ដើមដោយមានប្រថាប់ត្រាធនាគារ)។

## ៣. កំណត់ចំណាំ

ឯកសារទាំងអស់ត្រូវតែភ្ជាប់ជាមួយនឹងពាក្យសុំទិដ្ឋាការ។ គ្មានឯកសារណាមួយត្រូវបានផ្ញើដោយផ្ទាល់ទៅទីភ្នាក់ងារកុងស៊ុលក្នុងទីក្រុងភ្នំពេញ ឬមជ្ឈមណ្ឌលកុងស៊ុលប្រចាំតំបន់នៅទីក្រុងបាងកកឡើយ។ ឯកសារទាំងអស់ជាភាសាខ្មែរត្រូវតែត្រូវបកប្រែជាភាសាអង់គ្លេស ឬជាភាសាផ្លូវការណាមួយរបស់ប្រទេសស្វីស ៖ បារាំង/ អាឡឺម៉ង់/ អ៊ីតាលី ដោយទីភ្នាក់ងារបកប្រែ ដែលត្រូវបានទទួលស្គាល់ដោយមជ្ឈមណ្ឌលកុងស៊ុលប្រចាំតំបន់នៅទីក្រុងបាងកក។ ពាក្យសុំទិដ្ឋាការដែលមានលក្ខណៈមិនពេញលេញអាចជាឧបសគ្គក្នុងការផ្តល់ទិដ្ឋាការដល់ការស្នើសុំនោះ។ ឯកសារច្បាប់ដើមនឹងត្រូវបានត្រឡប់ទៅអ្នកស្នើសុំវិញបន្ទាប់ពីនីតិវិធីត្រូវបានបញ្ចប់។

## ៤. តំលៃ

ព័ត៌មានស្ដីពីតំលៃទិដ្ឋាការគឺអាចរកបាននៅទីនេះ។

## ៥. សេចក្ដីបញ្ជាក់នៃការគាំទ្រ

មជ្ឈមណ្ឌលកុងស៊ុល ប្រចាំតំបន់នៅទីក្រុងបាងកកអាចតម្រូវអោយបញ្ជូននូវសេចក្ដីបញ្ជាក់នៃការគាំទ្រ ដើម្បីផ្ទៀងផ្ទាត់ពាក្យស្នើសុំប្រសិនបើអ្នកស្នើសុំនោះមិនមានមធ្យោបាយហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីគាំទ្រការស្នាក់នៅក្នុងប្រទេសស្វីស ឬប្រសិនបើមជ្ឈមណ្ឌលកុងស៊ុលប្រចាំតំបន់នៅទីក្រុងបាងកកមានហេតុផលក្នុងការបញ្ជាក់នូវហិរញ្ញវត្ថុនៃការគាំទ្ររបស់អ្នកស្នើសុំមិនគ្រប់គ្រាន់។ គំរូនៃសេចក្ដីបញ្ជាក់នៃការគាំទ្រនឹងត្រូវផ្ដល់ដោយមជ្ឈមណ្ឌលកុងស៊ុលប្រចាំតំបន់នៅទីក្រុងបាងកកដោយផ្ទាល់។ ឯកសារនេះមិនអាចបានទាញយកបានទេ។

អ្នកធានាអាចជារូបវ័ន្តបុគ្គល (ជនជាតិស្វីសពេញវ័យ) ឬជនជាតិនៃរដ្ឋ Liechtenstein ឬជនបរទេសពេញវ័យកាន់លិខិតអនុញ្ញាតអោយស្នាក់នៅ៖លិខិតអនុញ្ញាតប្រភេទខ ឬលិខិតអនុញ្ញាតអោយបំពេញការងារ៖ លិខិតអនុញ្ញាតប្រភេទគរបស់ប្រទេសស្វីសដែលនៅមានសុពលភាព និងនីតិបុគ្គលដែលបានចុះក្នុងបញ្ជីពាណិជ្ជកម្ម។ នៅពេលដែលមជ្ឈមណ្ឌលកុងស៊ុលប្រចាំតំបន់នៅទីក្រុងបាងកកទាមទារឱ្យមាន សេចក្ដីបញ្ជាក់នៃការគាំទ្រអ្នកស្នើសុំទិដ្ឋាការត្រូវបំពេញសំណុំបែបបទដែលបានផ្ដល់ឱ្យ និងផ្ញើសំណុំបែបបទនោះទៅអ្នកធានានៅប្រទេសស្វីសតាមរយៈប្រៃសណីយ៍ អ៊ីម៉ែល ឬទូរសារ។ អ្នកធានាត្រូវបំពេញ និងចុះហត្ថលេខាលើទំរង់បែបបទនៃសេចក្ដីបញ្ជាក់នៃការគាំទ្រហើយត្រូវយកទៅដាក់ជូនអាជ្ញាធរមានសមត្ថកិច្ចថ្នាក់សង្កាត់ ឬសហគមន៍។ ព័ត៌មានលម្អិតស្ដីពីនិតិវិធីនៃសង្កាត់នីមួយៗអាចរកបាននៅលើខិត្តប័ណ្ណព័ត៌មាន។ អាជ្ញាធរមានសមត្ថកិច្ចធ្វើការផ្ទៀងផ្ទាត់សេចក្ដីបញ្ជាក់នៃការគាំទ្រហើយជូនដំណឹងទៅ ការិយាល័យអន្តោប្រវេសន៍ថ្នាក់សង្កាត់ស្ដីពីផលនៃការផ្ទៀងផ្ទាត់ក្រោមទំរង់ជាលិខិតបញ្ជាក់ជំហមួយ។ លិខិតនេះត្រូវបានបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិចទៅមជ្ឈមណ្ឌលកុងស៊ុលប្រចាំតំបន់នៅទីក្រុងបាងកក។ អ្នកស្នើសុំទិដ្ឋាការឬតតិយជន(ជនទីបីដែលមានសិទ្ធិ) ដែលបានអនុញ្ញាតអាចដាក់លិខិតឆ្លងដែន ការកក់សំបុត្រយន្តហោះ និងការធានារ៉ាប់រងសុខភាពពេលធ្វើដំណើរថ្មីទៅតាមកាលបរិច្ឆេទថ្មីនៃការស្នាក់នៅ(បើមាន) នៅឯការិយាល័យរបស់ទីភ្នាក់ងារកុងស៊ុលនៅក្នុងរាជធានីភ្នំពេញក្នុងអំឡុងពេល ម៉ោងធ្វើការ និងដោយពុំចាំបាច់ធ្វើការណាត់ជួបជាមុនឡើយ។ លិខិតឆ្លងដែន នឹងត្រូវបញ្ជូនទៅមជ្ឈមណ្ឌលកុងស៊ុលក្នុងប្រចាំតំបន់នៅ ទីក្រុងបាងកកតាមរយៈកញ្ចប់សំបុត្រប្រចាំសប្ដាហ៍សម្រាប់ការសម្រេចចុងក្រោយ និងបញ្ជូនត្រឡប់មកកាន់រាជធានីភ្នំពេញវិញនៅ សប្ដាហ៍បន្ទាប់។ ទីភ្នាក់ងារកុងស៊ុលនៅក្នុងរាជធានីភ្នំពេញ នឹងជូនដំណឹងដល់អ្នកស្នើសុំទិដ្ឋាការក្រោយពីបានទទួលលិខិតឆ្លងដែន។

ទីក្រុងបាងកក ថ្ងៃ ទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៧